ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា
លេខ ធ៧-០១៦-១១៧ ប្រ.ក

# ប្រកាស
# ស្តីពី
# ដើមទុនចុះបញ្ជីអប្បបរមា
# របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.កចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ៧-០០-០៦ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- យោងប្រកាសលេខ ធ៧-០៧-១៦៣ ប្រ.ក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីសាធារណជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- យោងប្រកាសលេខ ធ៧-០៨-១៩៣ ប្រ.ក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជីនិងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារ
- យោងស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

## សម្រេច

**ប្រការ ១**.-

ប្រកាសនេះមានគោលបំណងកំណត់ឡើងវិញនូវដើមទុនចុះបញ្ជីអប្បបរមា ចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។

**ប្រការ ២**.-

ប្រកាសនេះមានគោលដៅពង្រឹងមូលដ្ឋានដើមទុនឲ្យកាន់តែរឹងមាំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៣**.-

ធនាគារពាណិជ្ជបង្កើតឡើងក្រោមរូបភាពជាសាខាធនាគារបរទេស ដែលមានធនាគារមេ មានចំណាត់ថ្នាក់វិនិយោគដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមា ស្មើនឹង ២០០.០០០.០០០.០០០ រៀល (ពីររយប៊ីលានរៀល) ។

ក្នុងករណីធនាគារមេនៅបរទេសធ្លាក់ចំណាត់ថ្នាក់ក្រោមចំណាត់ថ្នាក់វិនិយោគ ធនាគារត្រូវរាយការណ៍ជាបន្ទាន់មកធនាគារជាតិនៃកម្ពុជា ។

ចំពោះធនាគារពាណិជ្ជជាសាខាធនាគារបរទេសដែលធនាគារមេមិនមានចំណាត់ថ្នាក់វិនិយោគ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមា ដូចធនាគារដែលមានចែងក្នុងប្រការ ៤ ។

**ប្រការ ៤**.-

ធនាគារពាណិជ្ជដែលបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុនក្នុងស្រុក ឬជាបុត្តសម្ព័ន្ធធនាគារបរទេស ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ៣០០.០០០.០០០.០០០ រៀល (បីរយប៊ីលានរៀល) ។

**ប្រការ ៥**.-

ធនាគារឯកទេសបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុនក្នុងស្រុក ត្រូវមានដើមទុនចុះបញ្ជីអប្បបរមា ស្មើនឹង ៦០.០០០.០០០.០០០ រៀល (ហុកសិបប៊ីលានរៀល) ។

**ប្រការ ៦**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើត្រូវមានដើមទុនចុះបញ្ជីអប្បបរមាស្មើនឹង ១២០.០០០.០០០.០០០ រៀល (មួយរយម្ភៃប៊ីលានរៀល) ។

**ប្រការ ៧**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវមានដើមទុនអប្បបរមាស្មើនឹង ៦.០០០.០០០.០០០ រៀល (ប្រាំមួយប៊ីលានរៀល) ។

**ប្រការ ៨**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបំពេញដើមទុនឱ្យបានគ្រប់តាមកម្រិតដើមទុនអប្បបរមាដូចមានចែងក្នុងប្រការ ៣ ប្រការ ៤ ប្រការ ៥ ប្រការ ៦ និងប្រការ ៧ នៃប្រកាសនេះ ក្នុងរយៈពេលពីរឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រការ ៩.-**

ត្រូវបានចាត់ទុកជានិរាករណ៍ ៖

- ប្រការ៤ នៃប្រកាសលេខ ធ៧-០០-០៦ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- ប្រការ២ ចំណុច៣ នៃប្រកាសលេខ ធ៧-០៧-១៦៣ ប្រ.ក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការផ្តល់អាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីសាធារណជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង
- ប្រការ៧ ប្រការ៨ និងប្រការ១០ នៃប្រកាសលេខ ធ៧-០៨-១៩៣ ប្រ.ក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជីនិងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណ ចំពោះគ្រឹះស្ថានធនាគារ ។

**ប្រការ ១០.-**

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋានអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងអគ្គនាយកគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១១.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦

**ទេសាភិបាល**

ធនាគារជាតិនៃកម្ពុជា

**ជា.ចាន់តូ**

**__កន្លែងទទួល៖__**

- ដូចប្រការ ១០ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**__ចម្លងជូន៖__**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"